C45

*Cassava Production*

C45

# ដំឡូងឈើ






គំរោងឥណទានកម្មវិធី ធនាគារ អភិវឌ្ឍន៍ អាស៊ី

(ADB) លេខ 1445-CAM ( SF )

នាយកដ្ឋាន ផ្សព្វផ្សាយកសិកម្ម

លេខ : ២ ឆ្នាំ ២០០៣


011

## ១_សារៈប្រយោជន៍របស់ដំឡូងឈើ :

ដំឡូងឈើជាដំណាំអាហារមួយប្រភេទ ដែលអាចហូបជំនួសបាយបាន នៅពេលអ្នកខ្វះអង្ករ ។ ក្រៅពីធ្វើជាអាហាររបស់ មនុស្ស គេអាចយកទៅធ្វើជាចំណីសត្វបានយ៉ាងល្អ ស្លឹកដំឡូងឈើ គេអាចយកទៅធ្វើជាបន្លែស្រស់ អន្ទក់ ។ល ។ គេអាចយកម្សៅដំឡូងឈើធ្វើជា នំប៉ុងជំនួសស្រូវសាឡីបាន ជាងនេះទៅទៀត ដំឡូងឈើក៏ជាវត្ថុធាតុដើមរបស់រោងចក្រសំរាប់ផលិតក្រដាសធ្វើ ជ័រ ។

## ២_ប្រភេទពូជ :

ដំឡូងឈើដែលគេនិយមដាំនៅក្នុងប្រទេសកម្ពុជាយើងមានពូជនាំមកពីបរទេស និង ពូជនៅក្នុងស្រុក ពូជទាំងនោះមាន ពូជស្រាល និងពូជធ្ងន់ ។ បើគេបែងចែកពូជទៅតាមលក្ខណៈ មើមរបស់ដំឡូងក៏មានពីរប្រភេទដែរគឺ :

*ក-ពូជដែលមនុស្សហូបមើម :*

ពូជនេះ មើមរបស់វាមានសាច់មើមម៉ដ្ឋរសជាតិផ្អែមច្រើនជាងល្វីងហើយវាជាពូជដែលធន់ទ្រាំទៅនឹងការរាំងស្ងួត និង មានរយៈពេលលូតលាស់ខ្លី គឺ ៨_១២ ខែ ។

*ខ-ប្រភេទពូជសំរាប់ធ្វើម្សៅនិងចំណីសត្វ :*

ពូជនេះ មើមរបស់វាមានសាច់មើមគ្រើមមិនស្វិតមានរសជាតិល្វីងទាំងអស់ ។ ប្រភេទពូជនេះមានរយៈពេលលូតលាស់វែង ។

**៣_បច្ចេកទេសដាំដុះ :**

*៣.១-ការធ្វើដី :*

- អ្នកត្រូវកាប់ឬភ្ជួរដីអោយបានជំរៅប្រហែលពី *២០_៣០ស.ម* ភ្ជួរឱ្យបានពីរទៅបីដងដើម្បីឱ្យដីផុសល្អ បន្ទាប់មកអ្នកត្រូវរើសយកស្មៅចេញអោយបានស្អាត ។

- អ្នកត្រូវហាលដីអោយបានស្ងួតល្អ ។



*ការរៀបចំហាលដី*



*៣.២-ការរើសពូជ :*

- អ្នកត្រូវរើសយកដើមដំឡូងណា ដែលធំមានលក្ខណៈដុះលូតលាស់ល្អ និង មានអាយុកាលយ៉ាងតិចមួយឆ្នាំ ។

- អ្នកត្រូវកាត់ជាកង់ៗ *ប្រវែងពី ១៥_២០ស.ម* ។

*៣.៣-រដូវកាលដាំដុះ :*

អ្នកគួរដាំដំឡូង នៅពេលដែលដីមានសំណើមគ្រប់គ្រាន់ ហើយសំណើមនៅក្នុងដីនោះអាចធានានូវការលូតលាស់របស់ដំឡូង ក្នុងរយៈពេល៤_៥ខែ ដូច្នេះពេលវេលាដ៏សមស្រប និងល្អបំផុតនោះ គឺក្នុងអំឡុងខែវិច្ឆិកា និងធ្នូ ជាពិសេសបន្ទាប់ពីទឹកទន្លេស្រកចុះ ។

*៣.៤-វិធីសាស្ត្រដាំដុះ :*

*ការដាំដំឡូងឈើជាទូទៅគេដាំតាមបីរបៀប:*

**ក-ការដាំបញ្ឈរ :**

ការដាំតាមវិធីនេះ អ្នកត្រូវដាក់កំណាត់ដំឡូងឈើរាងបញ្ឈរដែលមានមុំពី ២០_៤៥ ដឺក្រេ ដោយប្រៀបធៀបទៅនឹងដី ។ ជាទូទៅការដាំអ្នកត្រូវកប់ដើមដំឡូងឈើផ្នែកខាងក្រោមនៃដងដើម ទៅក្នុងដីអោយជ្រៅ ជួនកាលអ្នកអាចកប់ដីជិតតែម្តង ឬ ទុកផ្នែក ខាងចុងដើមលេចផុតពីដីបន្តិច ។



*ការបង្ហាញពីរបៀបដាំបញ្ឈៀង*

## ខ-ការដាំផ្ដេក

ការដាំរបៀបនេះអ្នកត្រូវដាក់ដើមដំឡូងផ្ដេកនៅក្នុងជួរតែម្ដង ឬ បាតរងតែម្ដងរួចអ្នកត្រូវកប់ដីពីលើដែលមានកំរាស់ *ពី ៥-១០ ស.ម។*



*ការបង្ហាញពីរបៀបដាំផ្ដេក*



## គ-ការដាំបញ្ឈរ

ការដាំរបៀបនេះ អ្នកត្រូវដាំដើមដំឡូងបញ្ឈរក្នុងដីតែម្ដង គឺអ្នកត្រូវកប់ផ្នែកចាស់នៃដើមទៅក្នុងដី ហើយទុកផ្នែកខាងចុងនៅផុតពីដី ។

ចំពោះវិធីសាស្ត្រទាំងបីខាងលើនេះ ជាទូទៅគេច្រើននិយមដាំតាមរបៀបបញ្ឈៀង ឬ ផ្ដេកហើយ ពីព្រោះវាផ្ដល់ទិន្នផលខ្ពស់ ។



*ការបង្ហាញពីរបៀបដាំបញ្ឈរ*

## ឃ-ចន្លោះឃ្លាត

| ចន្លោះពីជួរ១ទៅជួរ១ | ចន្លោះពីដើម១ទៅដើម១ | ចំនួនដើម |
|---|---|---|
| ៩០ ស.ម | ៦០ ស.ម | ១៨ ០០០ ដើម/ហិកតា |
| ៩០ ស.ម | ៩០ ស.ម | ១២ ០០០ ដើម/ហិកតា |
| ៩០ ស.ម | ១២០ ស.ម | ៩ ០០០ ដើម/ហិកតា |

ប៉ុន្តែជាទូទៅគេច្រើនដាំដំឡូងឈើ ក្នុងចន្លោះពីគុម្ពមួយទៅ គុម្ពមួយប្រវែងមួយម៉ែត្រ ហើយចន្លោះពីជួរមួយទៅជួរមួយគឺប្រវែង មួយម៉ែត្រដែរ ។



*ចន្លោះពីគុម្ពមួយទៅគុម្ពមួយ ១ ម៉ែត្រ*

## *ខ-ជម្រៅដែលត្រូវដាំ*

អ្នកត្រូវប្រើចបជីកឬចបកាប់ ដើម្បីកាប់ដីអោយបានជម្រៅពី *៧.១០ស.ម* ហើយកប់កំណាត់ដំឡូងទៅតាមស្នាមចបនោះ ។

### *៣.៥-ការប្រើជី :*

- ប្រភេទជីដែលអ្នកត្រូវប្រើនោះ គឺ ជីប្រភេទ ៨.១៦.១៩ ដាក់ក្នុងចំនួនពី ៦០.១០០ គីឡូក្រាមក្នុងផ្ទៃដី ១៦០០ សង់ទីម៉ែត្រ ការ៉េ ។



លើកទី១នៅពេលដែលដំឡូងមានអាយុបានមួយខែបន្ទាប់ពីដាំ ។ ដាក់លើកទីពីរ នៅពេលដែលដំឡូងមានអាយុបីខែក្រោយពីដាំ ហើយត្រូវដាក់អោយបានឆ្ងាយពីគល់ដំឡូងបន្តិច គឺប្រហែលពី *២៥.៣០ស.ម* ហើយលុបដី ។

### *៣.៦-ការថែទាំ :*

- ក្រោយពីដាំដំឡូងបានពី ៥ . ៧ ថ្ងៃ ត្រូវពិនិត្យមើលការដុះពន្លករបស់ដំឡូង អ្នកត្រូវដាំជួសឡើងវិញ ជាបន្ទាន់ចំពោះកន្លែងណាដែលមិនដុះ ។

- បន្ទាប់ពីដំឡូងមានអាយុ ៣០ ថ្ងៃ ត្រូវជ្រួយដី បោចស្មៅ អោយបានស្អាតល្អដើម្បីឱ្យដីផុសត្រសុសល្អ ។



*ការសំអាតស្មៅ*

- គួរសំអាតស្មៅអោយបានស្អាតនៅចន្លោះរងដំឡូង ដើម្បីអោយដំឡូងដុះលូតលាស់ល្អ ហើយនៅពេលធ្វើស្មៅ និងជ្រួយដី ត្រូវប្រយ័ត្នប្រយែងកុំអោយប៉ះទង្គិចដល់ឫសរបស់ដំឡូង ជាពិសេសនៅពេលដែលដំឡូងកំពុងចុះមើម ។

*៣.៧-ការប្រមូលផល*

ការប្រមូលផល វាអាស្រ័យទៅតាមពូជរបស់ដំឡូងឈើ ចំពោះពូជស្រាលត្រូវប្រមូលផលនៅពេលដែលដំឡូងមានអាយុ ៩-១០ ខែ ចំពោះពូជធ្ងន់ត្រូវប្រមូលផល នៅពេលដែលដំឡូងមាន អាយុ១២-១៣ខែ ។ ការប្រមូលផលមានពីររបៀបគឺដោយដៃ និង ដោយពាក់កណ្ដាលយន្តសាស្ត្រ ។

*ក-ការប្រមូលផលដោយដៃ*

អ្នកត្រូវកាប់ដើមដំឡូងឈើចោលជាមុនសិន ដោយទុកដងដើមត្រឹមតែកំពស់ប្រមាណ*២០-៥០ស.ម* ការកាប់ដើមនោះ គឺងាយស្រួលក្នុងការដក ។ ពេលដកមើមអ្នកត្រូវរញ្ជួយ ឬ រង្គៀកដើមជាមុនសិន ទើបចាប់ផ្ដើមដកបន្តិចម្ដងៗ ធ្វើយ៉ាងនេះគឺដើម្បីជៀសវាងការបាក់មើម របាត់សំបកមើម ។វិធីម្យ៉ាងទៀតត្រូវកាប់ដងដើម មួយផ្នែកចោល ហើយបន្ទាប់មកត្រូវទុកចោលពី ៧-១៤ ថ្ងៃ សិន ទើបចាប់ផ្ដើមដក ។





*ការប្រមូលផលដោយដៃ*

*ខ-ការប្រមូលផលដោយពាក់កណ្ដាលយន្តសាស្ត្រ*

ការងារនេះគឺជាការរួមផ្សំនិងឧបករណ៍ផ្សេងៗ ព្រមទាំងកំលាំងមនុស្ស ។

**៤-ការទុកដាក់ :**

មើមដំឡូងឈើជាទូទៅគឺមិនអាចធានាទុកបានយូរពេកទេ ពីព្រោះវាងាយរលួយខូចណាស់ គឺបណ្ដាលមកពីការរលួយខ្លួនវា និងបណ្ដាលមកពីមេរោគឬជំងឺផ្សេងៗ ។ គេអាចជៀសវាងចំពោះការរលួយរបស់ដំឡូងបានគឺតាមរយៈការរក្សាទុកមើមដំឡូងនោះ ដោយកប់ក្នុងដីឬកប់ក្នុងដីខ្សាច់សើម ឬដាក់មើមតំរៀបគ្នាក្នុងចាវសើមឬរុំដោយក្រដាសសើម ។ គេអាចរក្សាទុកមើមដំឡូងក្នុងរយៈពេល

យូរបាន ដោយទុកវានៅក្នុងទូ ឬ បន្ទប់ត្រជាក់ដែលមានសីតុណ្ហភាព ២៥ អង្សាសេ ព្រមទាំងស្ថិតក្នុងសំណើមអាកាសពី ៨៥-៩០% ។

វិធីទុកម្យ៉ាងទៀតគឺគេចិតមើមដំឡូងនោះស្តើងៗ ហាលឱ្យស្ងួតរហូតដល់មានសំណើមក្នុងមើមដំឡូងនោះត្រឹម១០-១២% ប៉ុណ្ណោះ ។ គេអាចបន្ថយនូវការរលួយមើមបានមួយកំរិតតាមរយៈការកាប់ដើមចោលមុនពេលប្រមូលផលក្នុងរយៈពេលប្រមាណពី ៧-២១ ថ្ងៃ ។ ការទុកដាក់ដោយខ្ចប់ក្រដាសសើម គឺអាចបន្ថយភាពរលួយបានមួយកំរិត បើប្រៀបធៀបទៅនឹងការទុកដាក់ធម្មតា ។ បើក្នុងករណីដែលគេត្រូវនាំចេញមើមស្រស់ទៅលក់នៅកន្លែងឆ្ងាយ ឬប្រទេសឆ្ងាយ គឺ គេគួរតែប្រមូលផលនៅពេលដែលដំណាំមាន អាយុមិនលើសពី១០ខែ បន្ទាប់ពីដាំ ។

## ៥-ជំងឺនិងសត្វល្អិតចង្រៃ :

### ក-ជំងឺរលួយឫស :

ជំងឺនេះបង្កឡើងដោយពពួកផ្សិត ដោយវារាតត្បាតទៅលើប្រព័ន្ធឫសដែលស្ថិតនៅក្នុងដីនៃដំណាំនេះ ហើយធ្វើឱ្យរលួយភាគច្រើន នៅក្នុងរដូវភ្លៀង និងស្ថិតនៅក្នុងដីកណ្តៀងជាំទឹក ព្រមទាំងមានជីធម្មជាតិច្រើន ។ មេរោគនៃជំងឺនេះច្រើនរាតត្បាតនៅលើ



ដីជាំទឹក ។ រោគសញ្ញានៃជំងឺនេះ វាធ្វើអោយដើមដងស្រពោនងាប់បន្តិចម្តងៗ ថែមទាំងបញ្ចេញនូវទឹកម្យ៉ាងដែលមានក្លិនស្អុយបន្ទាប់មកប្រព័ន្ធឫសរបស់ដំឡូងរលួយទាំងអស់តែម្តង ។

គេអាចជៀសវាង ជំងឺនេះបានតាមរយៈការជ្រើសរើសដីដែលមានលក្ខណៈសមស្របល្អមិនជាំទឹក ឬ នៅកន្លែងដែលមានទឹកជាប្រចាំ ។

### ខ-ជំងឺរលួយដើមដោយបាក់តេរី :

ដំឡូងដែលទទួលរងនូវជំងឺនេះ គេអាចសង្កេតឃើញនៅត្រួយ ឬ ពន្លកថ្មីរបស់វាក្រៀមស្វិត ហើយមានភាពរលួយសើមនៅលើដងដើម នៅលើផ្ទៃនៃដងដើមគេសង្កេតឃើញមានរន្ធតូចៗពាសពេញ ។ រន្ធទាំងនោះមានលក្ខណៈពិសេសមួយ ដែលងាយស្រួលក្នុងការកំណត់ចំណាំ គឺគេឃើញមានជ័រស្ងួត ។ ពេលដែលគេកាត់ ដើមដែលមានជំងឺនេះមានលក្ខណៈក្រិនទាប និងប្រព័ន្ធឫសលូតលាស់ខ្សោយបំផុត។ គេអាចជៀសវាងបញ្ហានេះបានដោយគ្រាន់ តែជ្រើសរើសដើមណាដែលមានសុខភាពល្អយកទៅធ្វើពូជឬជ្រើសរើសយកពូជធន់នឹងជំងឺនេះ ។

## ៦-ផ្លែលោះសារូបត្ថម្ភ :

**ដំឡូងឈើ**ជាប្រភេទដំណាំមើមមួយមុខដែលកសិករខ្មែរ

យើងនិយមដាំជាងគេ ។ ក្រៅពីមើមរបស់ដំឡូងឈើនៅតាមទីជនបទខ្លះៗ គេនៅនិយមយកត្រួយស្លឹកទៅធ្វើជាបន្លែ បានយ៉ាងឆ្ងាញ់ពិសាទៀតផង។ ក្នុងស្លឹកត្រួយដំឡូងឈើក៏មានទូវីតាមីនអាខ្លះដែរ ដែលអាចជួយការពារជំងឺភ្នែកនានារបស់កុមារតូចៗបាន ។ ក្នុងមើមដំឡូងឈើសំបូរទៅដោយជាតិម្សៅ ដែលអាចឱ្យបរិភោគជាអាហារទ្រទ្រង់រាងកាយបានយ៉ាងប្រសើរ ។ ដូច្នេះក្នុងកាលៈទេសៈខ្វះខាតស្បៀង ដំឡូងឈើមានតួនាទីសំខាន់សំរាប់ទ្រទ្រង់រាងកាយកុមារក៏ដូចជា មនុស្សយើងគ្រប់រូបដែរ ។ ដំឡូងឈើគេអាចយកទៅកែច្នៃជាបន្លែសំរាប់មុខម្ហូបផ្សេងៗ ឬ ធ្វើជាបង្អែម ។ល ។ម្យ៉ាងទៀតក្រៅពីប្រើប្រាស់ជាផលប្រយោជន៍បានច្រើន ដំឡូងឈើជាប្រភេទដំណាំមើមដែលងាយដាំនឹងថែរក្សាបំផុត ដូចនេះគ្រួសារខ្មែរយើងគួរនាំគ្នាដាំទុក សំរាប់ជាប្រយោជន៍គ្រួសារកុំបីខាន ។